**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍**

លេខៈ ៥០៤ សត.ប្រក.០១៤

# ដីកាសម្រេចឱ្យបង្កកទ្រព្យ

## យើង អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍

- យោងមាត្រា ៧៩ នៃច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ឆ្នាំ ២០០៧
- យោងមាត្រា ៤ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ ២០០៧
- យោងមាត្រា ២៩ នៃច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧
- យោងអនុក្រឹត្យលេខ: ៩០ អនក្រ.បក ស្តីពីការបង្កកទ្រព្យសម្បត្តិរបស់ភេរវករ និងអង្គការនានា ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៤
- យោងតាមលិខិតលេខ: ៧៣៤ កយ.អនប/១៤ របស់ក្រសួងយុត្តិធម៌ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ បញ្ជាមកអគ្គព្រះរាជអាជ្ញាឱ្យចេញដីកាសម្រេចបង្កកទ្រព្យ ។

## <u>សម្រេច</u>

១- **បង្គាប់មក**បុគ្គលរាយការណ៍ដូចមានចែងក្នុង មាត្រា ៤ នៃច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឱ្យបង្កកទ្រព្យទាំងឡាយរបស់បុគ្គលដែលមានរាយឈ្មោះក្នុងបញ្ជី អាល់កៃដា និង តាលីបង់ ដូចមានជូនភ្ជាប់មកជាមួយជាបន្តបន្ទាប់ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ: ១២៦៧ ។

២- រាយការណ៍មកអគ្គព្រះរាជអាជ្ញា ក្រោយពីមានការបង្កកទ្រព្យ ដើម្បីមានវិធានការតាមផ្លូវច្បាប់បន្ត ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៤

**អគ្គព្រះរាជអាជ្ញា**

អ៊ុក សាវុធ